# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# សុន្ទរកថាគន្លឹះ

### របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

### នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### ថ្លែងនៅក្នុង

### កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥

*** + ***

***ឯកឧត្តម, លោកជំទាវ, សមាជិក- សមាជិកា នៃរាជរដ្ឋាភិបាល***

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ ជាទីមេត្រី !***

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តយស និងសេចក្ដីសោមនស្សក្រៃលែង ដែលបានមកចូលរួមជាមួយឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិទាំងអស់ នៅក្នុង «**កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ដ៏មានសារសំខាន។ ខ្ញុំសូមចូលរួមជាមួយឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ដើម្បីសដែងនូវកិចស្វាគមន៍យ៉ាងកក់ក្ដៅ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះឯកឧត្តម, លោកជំទាវ, អស់លោក លោកស្រីទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកិចប្រជុំនេះ។

ពិតណាស, ដូចឯកឧត្តមរដមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានគូសបញ្ជាក់ថា លទ្ធផលដែលយើងទទួលបានពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈកាល ១០ ឆ្នាំកន្លងទៅនេះ គឺពិតជាគួរជាទីលើកទឹកចិត្តមែន។ ប៉ុន្តែតាមគំនិតខ្ញុំ យើងគួរហ៊ានវាយតម្លៃថា នេះគឺជាលទ្ធផលដ៏គួរជាទីមោទនៈ។ ខ្ញុំធ្លាប់បានគូសបញ្ជាក់ហើយថា ក្នុងជីវិតជានាយករដ្ឋមន្ត្រី គឺពិតជាគ្មានអ្វីដែលធ្វើឱ្យខ្ញុំសប្បាយចិត្តជាងការលុបបំបាត់បានទាំងស្រុងនូវ

បំណុលសាធារណៈ និងការកែប្រែស្ថានភាពនៃការអនុវត្តថវិកា ពីស្ថានភាពខ្វះសាច់ប្រាក់ជំរ៉ាំរ៉ៃ មកជាការទូទាត់បានទាន់ពេលវេលាប៉ុណ្ណោះទេ, ក៏ប៉ុន្តែ យើងថែមទាំងបានឈានដល់ស្ថានភាពសម្រេចបានអតិរេកសាច់ប្រាក់ជាបន្ត-បន្ទាប់ ដែលធ្វើឱ្យការអនុវត្តថវិកាកាន់តែអាចជឿទុកចិត្តបាន ហើយរាជរដ្ឋាភិបាលក៏មានលទ្ធភាពបង្កើនចំណាយលើវិស័យអាទិភាពមួយចំនួនដូចជា វិស័យអប់រំ, សុខាភិបាល និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ព្រមទាំងអាចដោះស្រាយបានដោយជោគជ័យ នូវបច្ច័យអាក្រក់នៃវិបត្តិពីខាងក្រៅ និងគ្រោះមហន្តរាយធម្មជាតិផ្សេងៗគ្នា ក្នុងអំឡុងឆ្នាំ ២០០៩-២០១១, និងលើសពីនេះ, ជាបណ្ដើរៗ, ឈានទៅតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកង-កម្លាំងប្រដាប់អាវុធ ឱ្យបានកាន់តែសមរម្យ និងប្រកបដោយសមធម៌ថែមទៀតផង។ ក្នុងបរិការណ៍នេះ ខ្ញុំសូមសំដែងនូវការវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណ ជូនចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់** ក្នុងនាមឯកឧត្តមជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** ក្នុងនាមឯកឧត្តមជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំង **ឯកឧត្តម, លោកជំទាវ, ជាប្រធានក្រសួង-ស្ថាប័នទាំងអស់** ដែលបានខិតខំជំរុញ និងធ្វើការរួមគ្នា ប្រកបដោយភាពជាម្ចាស់, ការទទួលខុសត្រូវ និងស្មារតីសហការខ្ពស់, នាំឱ្យយើងសម្រេចបានជោគជ័យគួរជាទីមោទនៈទាំងនេះ។ ទន្ទឹមនឹងនេះ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណចំពោះ **ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់**, ទាំងទ្វេភាគី និងពហុភាគី, ដែលបានរួមចំណែកយ៉ាងសកម្មផ្ដល់នូវការគាំទ្រប្រកបដោយសុឆន្ទៈ, ទាំងហិរញ្ញវត្ថុ និងបច្ចេកទេស, ដល់គ្រប់ការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេសការ-កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ តាមរយៈការបង្កើននូវការប្រើប្រាស់ប្រព័ន្ធ និងយន្តការរបស់រាជ-រដ្ឋាភិបាល ដើម្បីបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការ និងក្នុងគោលដៅជំរុញកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ព្រមទាំងក្នុងបុព្វហេតុនៃការអភិវឌ្ឍកម្ពុជា។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

**ថវិកា** គឺជាឧបករណ៍នៃ **គោលនយោបាយ**។ មានន័យថា បើមានគោលនយោបាយត្រឹមត្រូវច្បាស់-លាស់ តែគ្មានថវិកាសម្រាប់អនុវត្តនោះទេ គឺយើងមិនអាចសម្រេចបាននូវបំណងប្រាថ្នាដែលយើងរំពឹងចង់បាននោះឡើយ, ហើយផ្ទុយទៅវិញ បើគ្មានគោលនយោបាយច្បាស់លាស់ទេ នោះថវិកាច្បាស់ជានឹងត្រូវបានប្រើប្រាស់ខ្ជះខ្ជាយឥតប្រយោជន៍ជាមិនខាន។ ក្នុងស្មារតីនេះ ខ្ញុំចង់គូសបញ្ជាក់ថា ថ្វីត្បិតនៅក្នុងកម្រិតម៉ាក្រូ យើងមានគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមច្បាស់លាស់ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុង «**យុទ្ធ-សាស្ត្រចតុកោណ**» របស់រាជរដ្ឋាភិបាល និងនៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ**, ប៉ុន្តែយើងក៏ត្រូវទទួលស្គាល់ដែរថា នៅក្នុងកម្រិតវិស័យ និងកម្រិតក្រសួង-ស្ថាប័ន យើងនៅមានសេចក្តីត្រូវការកែលម្អ និងពង្រឹងថែមទៀត នូវការកំណត់គោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់យើង ដើម្បីធានាសង្គតិភាពទៅនឹងគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមរបស់រាជរដ្ឋាភិបាលផង ក៏ដូចជាដើម្បីធានាភាពត្រឹមត្រូវច្បាស់លាស់ និងភាពអាចវាស់វែងលទ្ធផល ឬសមិទ្ធកម្ម បានផង។ ហេតុនេះ ការជំរុញបង្កើនគុណភាព និងស័ក្តិ-

សិទ្ធភាពនៃការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រថវិការបស់គ្រប់ក្រសួង-ស្ថាប័ន គឺជាការងារសំខាន់ចាំបាច់ និងបន្ទាន់ នៅក្នុងដំណើរឆ្ពោះទៅដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើង ដែលជា **កិច្ចដំណើរការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ។** ដូច្នេះ ដើម្បីឈានទៅធានាថា ថវិកាជាតិ គឺពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយជាតិដ៏ពិតប្រាកដមែននោះ, ខ្ញុំសូមគូសបញ្ជាក់ជាថ្មីម្តងទៀត អំពីការប្តេជ្ញាប្រកបដោយឆន្ទៈមោះមុតឥតរាថយរបស់រាជរដ្ឋាភិបាលក្នុងការបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈ **យុទ្ធសាស្ត្រជាជំហានៗ និងជាដំណាក់ៗ ដើម្បីធ្វើការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់-គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ** ដែលឆ្លើយតបទៅនឹងឧត្តមានុវត្តន៍ និងស្តង់ដារអន្តរជាតិ ឱ្យសម្រេចបានជាស្ថាពរ នៅឆ្នាំ ២០២៥។

ប្រាកដណាស់ថា ក្នុងរយៈកាលជាង ២ ទសវត្សរ៍កន្លងទៅនេះ យើងពិតជាមិនត្រឹមតែរក្សាបានយ៉ាងរឹងមាំនូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចប៉ុណ្ណោះទេ, តែថែមទាំងបានធ្វើឱ្យមានការរីកចម្រើនគួរជាទីមោទនៈលើគ្រប់វិស័យ, ទាំងវិស័យនយោបាយ, សេដ្ឋកិច្ច និងសង្គម។ ជាក់ស្តែង, ពីនីតិកាលមួយទៅនីតិកាលមួយទៀត ជាបន្តបន្ទាប់, នយោបាយនៅកម្ពុជាកាន់តែឈានទៅរកភាពចាស់ទុំ ដែលធ្វើឱ្យការអនុវត្តលទ្ធិប្រជាធិបតេយ្យ កាន់តែមានលក្ខណៈល្អប្រសើរឡើងជាលំដាប់ និងធ្វើឱ្យសេដ្ឋកិច្ចមានកំណើនខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ហើយអត្រានៃភាពក្រីក្រ ក៏ត្រូវបានកាត់បន្ថយជាងពាក់កណ្តាល គឺពីជាង ៤០% នៃប្រជាជន មកនៅត្រឹមក្រោម ២០% នៃប្រជាជន។ ប្រការនេះ មិនត្រឹមតែបញ្ជាក់ឱ្យឃើញថា កម្ពុជាបាន និងកំពុងដើរលើផ្លូវត្រូវ នៅក្នុងការស្តារកសាង និងអភិវឌ្ឍប្រទេស ក្រោយពីត្រូវបានរំដោះឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ និងសង្គ្រាមប៉ុណ្ណោះទេ, តែថែមទាំងបានឆ្លុះបញ្ចាំងឱ្យឃើញផងដែរ ពីការខិតខំប្រឹងប្រែងប្រកបដោយវីរភាព, ហ៊ានធ្វើ-ហ៊ានទទួលខុសត្រូវ, របស់រាជរដ្ឋាភិបាល ដើម្បីបុព្វហេតុប្រទេសជាតិយ៉ាងពិតប្រាកដ។ ច្បាស់ណាស់ថា ជោគជ័យ និងសមិទ្ធផលដ៏ធំធេងមិនអាចកាត់ថ្លៃបានទាំងអស់នេះ គឺពិតជាមិនអាចកាត់ផ្តាច់ចេញពីការកែលម្អនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានឡើយ ពីព្រោះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនត្រឹមតែមានមុខងារក្នុងការស្វែងរកថវិកា វិភាជថវិកា និងធានាការប្រើប្រាស់ថវិកាប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពប៉ុណ្ណោះទេ, តែថែមទាំងមានតួនាទីជាឃ្នាស់សេដ្ឋកិច្ច និងជាឧបករណ៍សម្រាប់បម្រើឱ្យគោលនយោបាយសាធារណៈរបស់ជាតិ ក្នុងគ្រប់ផ្នែក និងគ្រប់វិស័យថែមទៀតផង។

ទោះជាយ៉ាងណា យើងក៏ត្រូវតែទទួលស្គាល់ដែរថា ការណ៍ដែលយើងអាចគ្រប់គ្រងបានល្អប្រសើរនូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុកន្លងមក គឺដោយសារតែយើងមានគោលនយោបាយត្រឹមត្រូវ, ច្បាស់លាស់ និងមានការតាមដានត្រួតពិនិត្យជាប្រចាំ ប្រកបដោយភាពម៉ត់ចត់ក៏ពិតមែន, ក៏ប៉ុន្តែ ដោយសារតែប្រព័ន្ធរបស់យើង នៅពុំទាន់សុក្រឹត្យ ពោលគឺ ពុំទាន់មានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយពេញលេញនៅឡើយ, ទាំងក្នុង

ទិដ្ឋភាពនៃយន្តការ, រចនាសម្ព័ន្ធ និងសមត្ថភាពស្ថាប័ន ក៏ដូចជាក្នុងទិដ្ឋភាពនៃក្របខ័ណ្ឌគតិយុត្តិ, ការគ្រប់គ្រងរបស់យើងក៏បន្តស្ថិតនៅក្នុងស្ថានភាពលំបាក, មានភាពផុយស្រួយ, មានបរិយាប័ន្នទាប ព្រមទាំងមានស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពទាបនៅឡើយ។ ដោយយោងលើស្ថានភាពនេះហើយ ទើបរាជរដ្ឋាភិបាលបានកំណត់នូវគោលដៅប្រកបដោយមហិច្ឆិតា ក្នុងការកសាងប្រព័ន្ធគ្រប់គ្រងរដ្ឋមួយប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព, ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, តាមរយៈការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗមួយចំនួនពិសេសគឺការកែទម្រង់ស្នូលទាំងបី ដែលមានលក្ខណៈជាការកែទម្រង់ប្រព័ន្ធ ប្រទាក់ក្រឡាគ្នា នោះគឺ **ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការកែទម្រង់រដ្ឋបាលសាធារណៈ** ដើម្បីឈានឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងរដ្ឋមួយ ដែលឆ្លើយតបទៅនឹងឧត្តមានុវត្តន៍ និងស្តង់ដារអន្តរជាតិ នោះគឺ**ប្រព័ន្ធគ្រប់គ្រងផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ**។

ជាការពិត នៅកងការជំរុញអនុវត្តកិចការកែទម្រង់ប្រព័ន្ធទាំងអស់នេះ យើងក៏បានដឹងយ៉ាងច្បាស់ថា យើងនឹងត្រូវជួបប្រទះ និងពុះពារជំនះនូវបញ្ហាប្រឈម, ការលំបាក និងភាពស្មុគស្មាញមួយចំនួន ចៀសមិនផុត ហើយជួនកាលវាតម្រូវឱ្យយើងហ៊ានលះបង់ និងទទួលរងនូវការឈឺចាប់មួយចំនួនថែមទៀតផង។ ក៏ប៉ុន្តែ បើគិតអំពីអត្ថប្រយោជន៍ដែលយើងទទួលបាន ហើយនឹងបន្តទទួលបានពីការអនុវត្តការកែទម្រង់ទាំងនេះ ធៀបទៅនឹងថ្លៃដែលយើងត្រូវបង់, យើងច្បាស់ជាទទួលស្គាល់ថា វាពិតជាមានតម្លៃដ៏លើសលប់ ដូចពាក្យថា ***«គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ, ហើយក៏គ្មានកំណែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ»***។ ហេតុនេះហើយ ទើបខ្ញុំតែងគូសបញ្ជាក់ជារឿយៗ, ម្តងហើយម្តងទៀត, ថា ***«កែទម្រង់ គឺរស់, មិនកែទម្រង់ គឺស្លាប់»***។ មួយវិញទៀត ដំណើរការវិវត្តយ៉ាងលឿននៃសេដ្ឋកិច, សង្គម និងបចេកវិទ្យា នាយុគសម័យសកលភាវូបនីយកម្ម និងសមាហរណកម្ម មិនត្រឹមតែបាន និងកំពុងជំរុញឱ្យគ្រប់តួអង្គៈ ទាំងបុគ្គល, ទាំងស្ថាប័ន, ទាំងវិស័យឯកជន, ទាំងវិស័យសាធារណៈ, នៅក្នុងគ្រប់កម្រិតៈ ទាំងកម្រិតជាតិ, ទាំងកម្រិតតំបន់ និងទាំងកម្រិតអន្តរជាតិ, ធ្វើប្រតិបត្តិការប្រកបដោយភាពរស់រវើក ព្រមទាំងត្រៀមលក្ខណៈជានិចសម្រាប់ការកែលម្អ និងការកែទម្រង់ ឱ្យកាន់តែប្រសើរឡើងជាប្រចាំប៉ុណ្ណោះទេ, តែថែមទាំងតម្រូវឱ្យមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ និងទូលំទូលាយហួសពីព្រំសីមារបស់ខ្លួន ក្នុងការវិភាគ និងការធ្វើសេចក្តីម្រេចចិត្តទៀតផងដែរ ទើបអាចធានាបាននូវភាពប្រកួតប្រជែង និងការអភិវឌ្ឍប្រកបដោយចីរភាព។

សរុបសេចក្តីឱ្យខ្លីមកវិញ, បទពិសោធន៍ជាអន្តរជាតិ និងជាពិសេសបទពិសោធន៍ជាវិជ្ជមានរបស់កម្ពុជាខ្លួនឯងផ្ទាល់ក្នុងរយៈពេលកន្លងទៅនេះ បានបង្ហាញយ៉ាងច្បាស់ថា ***«ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន»*** ។ អាស្រ័យហេតុនេះហើយ ទើបរាជរដ្ឋាភិបាលនីតិកាលទី ៥ នេះ នៅតែបន្តដាក់ «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» នៅក្នុងលំដាប់ជួរទីមួយនៃបញ្ជីអាទិភាពនៃកិចការកែទម្រង់របស់ខ្លួន។

ក្នុងស្មារតីនេះ និងដើម្បីធានាអនុវត្តឱ្យបានជោគជ័យនូវ «**ការបញ្ចប់ដំណាក់កាលទី ២ និងឈានទៅចាប់ផ្តើមដំណាក់កាលទី ៣**» នៃការកែទម្រង់ដ៏មានសារៈសំខាន់នេះ ខ្ញុំសូមធ្វើការណែនាំ និងផ្តល់អនុសាសន៍មួយចំនួន ដូចខាងក្រោម៖

**ទី១- ការនាំមុខក្នុងការដឹកនាំ និងគាំទ្រចំពោះគ្រប់ក្រសួង-ស្ថាប័ន នៅតែជាការងារចាំបាច់ដែលត្រូវបន្តធ្វើ។** ដូច្នេះ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** និង**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ត្រូវបន្តដើរតួនាទីស្នូលជាអ្នកនាំមុខ ក្នុងការដឹកនាំ និងគាំទ្រកិច្ចដំណើរការកែទម្រង់នេះ ជាមួយគ្រប់ក្រសួង-ស្ថាប័នទាំងអស់។

**ទី២- ការរួមចំណែក និងកត្តាកំណត់ជោគជ័យត្រូវបាន និងកំពុងផ្ទេរកាន់តែច្រើនឡើងៗ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាស្ថាបនិកនៃប្រព័ន្ធ ទៅក្រសួង-ស្ថាប័នដែលជាអ្នកប្រើប្រាស់ប្រព័ន្ធ។** ដូច្នេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ដាច់ខាតត្រូវបង្កើនការចូលរួមឱ្យកាន់តែសកម្មជាងមុន, ត្រូវមានភាពជាម្ចាស់ និងការទទួលខុសត្រូវកាន់តែខ្ពស់ជាងមុន ក្នុងការដឹកនាំរៀបចំ និងអនុវត្តផែនការសកម្មភាពកែទម្រង់របស់ខ្លួន ឱ្យបានប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់ ជាពិសេស ក្នុងការធានាបន្តដឹកនាំអនុវត្តប្រកបដោយនិរន្តភាពនូវការងារកែទម្រង់នានា ដែលបានក្លាយទៅជាការងារប្រចាំថ្ងៃ។

**ទី៣- ការធានាសង្គតិភាព និងការបំពេញឱ្យគ្នាទៅវិញទៅមក រវាងការងារកែទម្រង់ទាំងបីដែលមានលក្ខណៈជាប្រព័ន្ធ នឹងរឹតតែមានសារៈសំខាន់ និងភាពចាំបាច់។** ប្រការនេះ ចង្អុលបង្ហាញអំពីសេចក្តីត្រូវការក្នុងការបន្តពង្រឹងការផ្សារភ្ជាប់ការដ្ឋានកែទម្រង់ទាំងអស់របស់រាជរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ ពិសេស **ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការងារកែទម្រង់រដ្ឋបាលសាធារណៈ** ដើម្បីធានាភាពប្រទាក់ក្រឡាគ្នា និងស៊ីចង្វាក់គ្នា ដោយរលូន និងមានសង្គតិភាព។

**ទី៤- ការបំពាក់ស្មារតី អំពីភាពចាំបាច់ និងភាពបន្ទាន់នៃការកែទម្រង់ គឺជាកិច្ចការមិនអាចខ្វះបានសម្រាប់ ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់។** ដូច្នេះ ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់នៃក្រសួង-សាប័នទាំងអស់ ត្រូវតែ បណ្តុះស្មារតីនៃភាពចាំបាច់ និងភាពបន្ទាន់នៃការងារកែទម្រង់ ក្នុងគោលដៅលើកកម្ពស់ឆន្ទៈ និងការចូលរួមប្រកបដោយភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ នៅក្នុងកិច្ចការកែទម្រង់ដើម្បីធានាជោគជ័យ និងចីរភាពនៃការងារ។

**ទី៥- ភាពជឿទុកចិត្តបាននៃថវិកាត្រូវបានចាប់ផ្តើមកសាងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប៉ុន្តែដើម្បីធានាចីរភាព កិច្ចការនេះគប្បីត្រូវបានបន្តពង្រឹង និងពង្រីកទៅគ្រប់ក្រសួង-ស្ថាប័នទាំងអស់។** ដូច្នេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវតែពង្រឹងការគ្រប់គ្រង និងការអនុវត្តថវិការបស់ខ្លួន ជាពិសេសត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំឱ្យបានសុក្រឹត និងអនុវត្តឱ្យបានត្រឹមត្រូវនូវកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសរបស់ខ្លួន ដែលជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់ សម្រាប់ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការអនុវត្តថវិកា និងការគ្រប់គ្រងសាច់ប្រាក់។

**ទី៦- គណនេយ្យភាពហិរញ្ញវត្ថុក៏ដូចគ្នាដែរ គឺកំពុងត្រូវបានបង្កើននៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប៉ុន្តែការងារនេះ គប្បីត្រូវបានពង្រឹង និងលើកកម្ពស់នៅគ្រប់ក្រសួង-ស្ថាប័ន ដើម្បីធានាឱ្យមានប្រព័ន្ធកត់ត្រា និងប្រព័ន្ធ**

**របាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុមួយប្រកបដោយស្តង់ដារឯកភាព, សង្គតិភាព, សុក្រឹតភាព, តម្លាភាព, គណនេយ្យភាព និងទាន់ពេលវេលា។** ដូច្នេះ គ្រប់ក្រសួង-ស្ថាប័នត្រូវតែរៀបចំឱ្យមានប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុត្រឹមត្រូវ, ច្បាស់លាស់, សុក្រឹត និងទាន់ពេលវេលា ព្រមទាំងមានសង្គតិភាពទៅនឹងស្តង់ដាររួមរបស់រាជរដ្ឋាភិបាល ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ទី៧-ការរៀបចំគោលនយោបាយកម្រិតក្រសួង និងកម្រិតវិស័យ គប្បីត្រូវបានបន្តកែលម្អ និងពង្រឹងថែមទៀត ដោយក្នុងនេះ ត្រូវធានាឱ្យបាននូវការឆ្លើយតបទៅនឹងគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមរបស់រាជរដ្ឋាភិបាលផង និងធានានូវភាពត្រឹមត្រូវ, ច្បាស់លាស់ និងភាពអាចវាស់វែងលទ្ធផលឬសមិទ្ធកម្មបានផង។** ដូច្នេះ គ្រប់ក្រសួង-ស្ថាប័នត្រូវតែបន្តពង្រឹង និងកែលម្អការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួនបន្ថែមទៀត ជាពិសេស ការរៀបចំគោលបំណងគោលនយោ-បាយចំនួន ២ និងកម្មវិធីចំនួន ៥ ជាមួយនឹងការកំណត់សូចនាករ និងគោលដៅឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ហើយអាចវាស់វែងលទ្ធផលបាន។

**ទី៨-ភាពសមស្របរវាងរចនាសម្ព័ន្ធគោលនយោបាយ និងរចនាសម្ព័ន្ធស្ថាប័ន គឺជាកត្តាដ៏សំខាន់សម្រាប់ធានាស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការងាររបស់ក្រសួង-ស្ថាប័នផង និងដើម្បីផ្តល់ភាពងាយស្រួលដល់ការកំណត់បន្ទាត់គណនេយ្យភាព និងយន្តការត្រួតពិនិត្យតាមដាន និងវាស់វែងលទ្ធផល ឬសមិទ្ធកម្មផង។** ដូច្នេះ គ្រប់ក្រសួង-ស្ថាប័នត្រូវតែពិនិត្យភាពសមស្របរវាងគោលនយោបាយ និងតម្រូវការនៃរចនាសម្ព័ន្ធស្ថាប័នចាំបាច់សម្រាប់បម្រើឱ្យការអនុវត្តសកម្មភាពការងារប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ដើម្បីធានាសម្រេចបានតាមគោលដៅនៃគោលបំណងគោលនយោបាយរបស់ខ្លួន។

**ទី៩-ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានមនុស្សប្រកបដោយផលិតភាព, ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព កាន់តែមានភាពចាំបាច់ និងសារៈសំខាន់ខ្លាំងឡើងនៅក្នុងដំណាក់កាលនៃការផ្លាស់ប្តូរប្រព័ន្ធនេះ។** ដូច្នេះ ទន្ទឹមនឹងការជំរុញការអនុវត្តកម្មវិធីជាតិស្តីពីការកែទម្រង់រដ្ឋបាលសាធារណៈ ២០១៤-២០១៨, គ្រប់ក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់ខ្ពស់លើការងារបណ្តុះបណ្តាល និងគ្រប់គ្រងមន្ត្រីរាជការរបស់ខ្លួន, មិនត្រឹមតែសម្រាប់ការងារប្រចាំ-ថ្ងៃនោះទេ តែថែមទាំងសម្រាប់ការងារកែទម្រង់ផងដែរ ពិសេសក្នុងការប្រើប្រាស់ប្រព័ន្ធថ្មីប្រកបដោយប្រសិទ្ធភាព និងចីរភាព។

**ទី១០-ការពង្រឹង និងការបង្កើនការអនុវត្តប្រព័ន្ធតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុង គឺជាចំណែកមួយដ៏សំខាន់ និងចាំបាច់ សម្រាប់ធានាការអនុវត្តប្រកបដោយជោគជ័យ នូវប្រព័ន្ធគ្រប់គ្រងដោយផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ ដែលយើងបាន និងកំពុងកសាងជាបណ្តើរៗនេះ។** ដូច្នេះ គ្រប់ក្រសួង-ស្ថាប័នត្រូវតែពិនិត្យលើភាពសមស្រប, ភាពគ្រប់គ្រាន់, ស័ក្តិសិទ្ធភាព, ប្រសិទ្ធភាព និងផលិតភាពនៃប្រព័ន្ធតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុងរបស់ខ្លួន ហើយឈានទៅពង្រឹង, ពង្រីក និងកែលម្អក្នុងករណីចាំបាច់ ឱ្យស្របទៅនឹងលក្ខខណ្ឌតម្រូវនៃប្រព័ន្ធគ្រប់គ្រងដោយផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ។

**ទី១១- «ទស្សនាទានស្តីពីការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០» ដែលត្រូវបានសម្រេចដាក់ឱ្យអនុវត្តនៅចុងនីតិកាលទី ៤ និងកំពុងត្រូវបានបន្តជំរុញអនុវត្តនៅក្នុងនិតិកាលទី ៥ នេះ តាមរយៈ «យុទ្ធ-សាស្ត្រចតុកោណ-ដំណាក់កាលទី ៣» គឺជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។** ថ្មីៗនេះខ្ញុំបានផ្តល់ការឯកភាពឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំបោះពុម្ពឯកសារ **«ទស្សនាទានស្តីពីការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០»** នេះ ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ ដូច្នេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវតែយកទស្សនាទាននេះធ្វើជាមូលដ្ឋាននៅក្នុងការរៀបចំផែនការសកម្មភាពកែទម្រង់ប្រព័ន្ធគ្រប់គ្រងថវិការបស់ខ្លួន, ជាបណ្តើរៗ, ឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងដោយផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ នៅឆ្នាំ ២០២០។

**ទី១២- សមត្ថភាពប្រមូលចំណូលប្រកបដោយស្ថិរភាព និងចីរភាព គឺជាគន្លឹះដ៏សំខាន់មួយ, ដំបូងបំផុត, គឺសម្រាប់ធានានូវភាពអាចជឿទុកចិត្តបាននៃថវិកា, ប៉ុន្តែ លើសពីនេះទៀត, គឺសម្រាប់ជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងសម្រាប់ការធានាសមធម៌សង្គម។** លើមូលដ្ឋាននេះ នាពេលថ្មីៗកន្លងមក រាជរដ្ឋាភិបាលបានសម្រេចអនុម័តនូវ **«យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨»** ដែលត្រូវបានដឹកនាំរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ យុទ្ធសាស្ត្រនេះ ទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសពីគ្រប់ស្ថាប័នប្រមូលចំណូលទាំងអស់ ទើបអាចសម្រេចបានជោគជ័យតាមការគ្រោងទុក, ថ្វីត្បិតតែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានតួនាទីនាំមុខក្នុងការដឹកនាំអនុវត្តក៏ដោយ។ យោងលើសារៈសំខាន់នៃការងារនេះដូចបានគូសបញ្ជាក់ខាងលើ, ខ្ញុំសូមឆ្លៀតឱកាសដ៏កម្រនៃការជួបជុំគ្នានាពេលនេះ ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ **«យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨»** ចាប់ពីពេលនេះតទៅ។

***ឯកឧត្តម, លោកជំទាវ, អស់លោក, លោកស្រី !***

ពិតណាស់ថា ទង្វើ និងសមិទ្ធផលរបស់យើងក្នុងរយៈកាលកន្លងទៅ បានបង្ហាញយ៉ាងច្បាស់ថា រាជ-រដ្ឋាភិបាលពិតជាមានឆន្ទៈយ៉ាងមោះមុតឥតរាថយ, ប្រកបដោយភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់, ក្នុងការអនុវត្តការកែទម្រង់លើគ្រប់វិស័យ នងកាន់តែស៊ីជម្រៅ។ យ៉ាងណាក៏ដោយ ខ្ញុំនៅតែចង់គូសបញ្ជាក់ម្តងហើយម្តងទៀតថា ការកែទម្រង់របស់យើង កើតចេញមកពីការយល់ឃើញដ៏ត្រឹមត្រូវរបស់យើងដោយខ្លួនឯង, គឺមិនមែនជាការធ្វើតាមការបង្គាប់បញ្ជារបស់អ្នកណានោះទេ។ មានន័យថា យើងបានដាក់ចេញ និងជំរុញអនុវត្តកិចការកែទម្រង់ទាំងអស់របស់យើង, ដោយឈរលើហេតុផល និងវិចារណភាពច្បាស់លាស់ ព្រមទាំងប្រកបដោយភាពជាម្ចាស់ និងវីរៈភាព, ហ៊ានធ្វើ-ហ៊ានទទួលខុសត្រូវ, ហើយធ្វើជាជំហានៗ និងជាដំណាក់កាលៗ, ទៅតាមលទ្ធភាព និងសមត្ថភាពជាក់ស្តែងរបស់យើង។ ដូច្នេះ ដរាបណាយើងនៅតែយល់ឃើញថា ***«ការកែទម្រង់ គឺជាការងារស្លាប់រស់របស់កម្ពុជា»*** ដរាបនោះយើងពិតជាគ្មានថ្ងៃស្កប់ស្កល់នឹងកិចការនេះទេ។ ផ្ទុយទៅវិញ យើងនឹងបន្តចាត់ទុកថាការ-កែទម្រង់ គឺជាការងារប្រចាំថ្ងៃរបស់យើង ដែលយើងត្រូវបន្តកែលម្អ, ពង្រឹង, ធ្វើឱ្យកាន់តែស៊ីជម្រៅ, បង្កើន និងពង្រីកសមត្ថភាព និងលទ្ធភាពរបស់យើង សំដៅប្រើប្រាស់ឱ្យបានកាន់តែប្រសើរបំផុត នូវសក្តានុពល និងកាលា-

នុវត្តភាពទាំងឡាយដែលយើងមាន ក្នុងគោលដៅតាមឱ្យទាន់សភាពការណ៍ និងដំណើរវិវត្តន៍នៃសង្គម, សេដ្ឋកិច, និងនយោបាយ ទាំងនៅក្នុងក្របខ័ណ្ឌប្រទេស, ក្របខ័ណ្ឌតំបន់ ក៏ដូចជាក្របខ័ណ្ឌពិភពលោក។

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវការវាយតម្លៃខ្ពស់ និងសូមកោតសរសើរដោយស្មោះ ចំពោះការខិតខំប្រឹងប្រែងយ៉ាងប្តូរផ្តាច់របស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់ របស់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការជំរុញអនុវត្ត «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ក្នុងរយៈពេលកន្លងទៅ, ប្រកបដោយសុឆន្ទៈ, ក្នុងភាពជាមាស់ និងការទទួលខុសត្រូវខ្ពស់, ដែលធ្វើឱ្យយើងសម្រេចបានជោគ-ជ័យគួរជាទីមោទនៈ។ ពិតណាស់ ដៃគូអភិវឌ្ឍន៍ទាំងឡាយរបស់កម្ពុជា ក៏មានចំណែកប្រកបដោយមោទនភាពផងដែរនៅក្នុងជោគជ័យដ៏សំខាន់នេះ។ ដូច្នេះ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះ ជូនចំពោះគ្រប់ដៃគអភិវឌ្ឍន៍ទាំងអស់ ដែលបានរួមចំណែកផ្តល់នូវហិរញ្ញប្បទាន និងការគាំទ្រខាងផ្នែកបចេកទេស ជាមួយនឹងការសម្របសម្រួលដ៏ល្អ តាមរយៈអភិក្រមគ្របដណ្តប់ទូទាំងវិស័យ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរឱ្យសុឆន្ទៈ, ភាពជាមាស់, ការទទួលខុសត្រូវ, កិចខិតខំប្រឹងប្រែង និងការរួមចំណែក ព្រមទាំងកិចសហប្រតិបត្តិការដ៏ល្អទាំងនេះ កាន់តែរីកដុះដាលរឹងមាំឡើងជាលំដាប់ថែមទៀត ដើម្បីធានាជំរុញអនុវត្ត «**បញ្ចប់ដំណាក់កាលទី ២ និងឈានទៅចាប់ផ្តើមដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ប្រកបដោយជោគជ័យតាមការរំពឹងទុក។

***ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់!***